M11/1/A1KHM/HP1/KHM/TZ0/XX

22110533

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A1 – HIGHER LEVEL – PAPER 1**
**KHMER A1 – NIVEAU SUPÉRIEUR – ÉPREUVE 1**
**KHMER A1 – NIVEL SUPERIOR – PRUEBA 1**

Wednesday 11 May 2011 (morning)
Mercredi 11 mai 2011 (matin)
Miércoles 11 de mayo de 2011 (mañana)

2 hours / 2 heures / 2 horas

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento.


© International Baccalaureate Organization 2011

*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

**១.**

## អ្នកណាផ្ញើអោយកូនកំព្រា

ធ្លាក់ខ្លួនកំព្រា ចិត្តកាយរងា
វិលវល់អារម្មណ៍ ស្រងាកស្រនោះ
ក្រៀមក្រោះក្រៀមក្រំ សោកស្តាយដំនំ
លោកពុកអ្នកម៉ែ ។

រូបកូនកំព្រា នឹកឃើញវេលា
មានម៉ែឪថៃ កូនសែន “កក់ក្តៅ”
ម៉ងសៅប្រួលប្រែ ទុក្ខសោកស្រាកល្ហែ
រីករាយស្រស់ស្រាយ ។

ម៉ែពុកបាត់សូន្យ លែងឃើញរូបកូន
លែងបានប៉ះកាយ លែងលឺសំដី
អ្វីៗបាត់ឆ្ងាយ លែងបានដោះស្រាយ
លែងលែងជានិច្ច ។

ជិតម៉ែក្បែរពុក បានសុខឥតទុក្ខ
សុភាពពាក្យពេចន៍ “រញង់រញង់”
ផៅពង្សឥតខ្វាច ស្មោះស្ម័គ្រឥតគេច
ស្អាតអនាម័យ ។

ម៉ែពុកមេត្តា សែនករុណា
មុទិតាថ្លៃ ឧបេក្ខាស្មោះ
ស្រាយស្រស់កែថ្នៃ តែងអធ្យាស្រ័យ
អោយកូនគ្រប់គ្នា ។

ម៉ែពុកល្អណាស់ រាប់អានក្មេងចាស់
ដឹងសុខទុក្ខគ្នា បំរើប្អូនបង
ឆ្លើយឆ្លងម្ចីម្នា គ្រាដល់វេលា
បនពតសំលាប់ ។

យី! បនគំរក់ បនខ្មៅស្រេកឈ្លក់
បនពាលវាយកាប់ បនខ្មៅអស់សាច់
ចិត្តដាច់ចងចាប់ ប្រហារឥតប្រាប់
កំសាកព្រៃផ្សៃ ។

ម៉ានយ៉ានស្វផាត ចៅចិត្រឆ្មៀវឆ្លាត
ឃុននារីឆ្មើងឆ្មៃ ចៅចេកកំព្រា
វិធារីក្ស័យ ណាវិនមិត្តថ្លៃ
មិនដូចកូនទេ ។

កូនសូមគោរព ជានិច្ចឥតឈប់
ដួងចិត្តឥតរេ វិញ្ញាណក្ខន្ធ
រួមកាន់ទុក្ខទ្វេ កំហឹងស្ថិតស្ថេរ
សងគុណពុកម៉ែ ។

ដកស្រង់ពីកំនាព្យ “អ្នកណាធ្វើអោយកូនកំព្រា”
និពន្ធដោយ ស កាពុន ឆ្នាំ ១៩៨២

២.

## កូនអកតញ្ញូ

កាលឃើញមុខកូនគាត់ដំបូង តាម៉ែនគាត់សប្បាយចិត្ត តែមិនទាន់បានប្រាំនាទីផង គាត់បែជាមានការអន់ចិត្តនឹងអាកប្បកិរិយារបស់កូនគាត់ទៅវិញ ព្រោះកូនគាត់មិនហៅគាត់អោយចូលក្នុងផ្ទះ រឺក៏ហៅអោយអង្គុយនៅជើងម៉ាឡើយ។ លុះគាត់លឺកូនសួរថា: “ពុកមកនេះ មានការអ្វីដែរ?” គាត់ទៅជាហួសចិត្តនឹងសំដីកូនគាត់ ធ្វើអោយគាត់អស់សំណើចក្នុងបំពង់ក ដោយបន្តវាចាភ្លាមថា:

— “ហាស់! ឱ! កូនសួរពុកថា ពុកមកនេះមានការអ្វីដែរឬកូន? សូមកុំភ័ន្តច្រឡំ ដូចប្រពន្ធឯងថាពុកមកសុំ ទាននោះមិនមែនទេ! តែពុកចង់សួរកូនថា កូនភ្លេចហើយឬនៅភូមិថ្មគោល?”

— “ពុក! កូនមិនភ្លេចទេ ភូមិកំណើតរបស់កូននោះ ហើយថែមទាំងកូននឹកមមៃទៅកាន់លោកពុក និងម៉ែនជានិច្ច តែកូនឆ្លៀតឱកាសទៅពុំបាន ព្រោះជាប់រវល់ក្នុងការងាររាជការពេក!”

— “ឱ! កូនរវល់ណាស់ហ្ន៎! មួយឆ្នាំជាពីរឆ្នាំ កូនខំធ្វើការគ្មានពេលសំរាកសោះ គ្រាន់តែសំបុត្រ ក៏កូនគ្មានពេលសរសេរទៅពុកដែរ តើកូនភ្លេចហើយឬនៅ កាលដែលកូនកំពុងនៅរៀន?”

— “កូនដឹងហើយពុក ហើយកូនពុំភ្លេចទេ ថាលោកពុកនិងម៉ែន ខំបញ្ចេញកំលាំង និងបង្ហូរញើស ដើម្បីផ្តល់នូវឋានៈអោយកូនបានថ្កុំថ្កើនប៉ុណ្ណេះនេះ តែសូមលោកពុកជួយគិតមើលប្រាក់ខែខ្ញុំ៤០០០រៀល ហើយចាយវាយគ្រប់ជំពូក ឯណាថ្លៃម្ហូបអាហារ “មឿនរាប់ដៃ” ឯណាពន្ធតាក់ ឯណាថ្លៃភ្លើង ថ្លៃទឹក ឯណាសាំងចាក់ឡាន ហើយប្រពន្ធខ្ញុំក៏ពុំសូវមានមាសពេជ្រពាក់ផង។ បើខ្ញុំរកក្រៅបានខ្លះទៅ នឹងឆ្លៀតផ្ញើទៅលោកពុកអោយបានញឹកញយ តែនេះប្រាក់ខែ ក៏ចាយពុំគ្រប់គ្រាន់ រកក្រៅក៏ពុំទាន់បាន កូនលំបាកចិត្តណាស់ពុក! មិនទាន់ធូរធារទេសព្វថ្ងៃនេះ!”

— “ហាស់ៗ ពិរោះណាស់កូន សំដីកូនពិរោះណាស់ ព្រោះកូនគិតដល់ពុកណាស់ដែរ តែកូនមិនទាន់ធូរធារ សូមកូនខំរកអោយបានចំរុងចំរើនទៅកូន ចំនែកពុកឈប់គិតទៅ ព្រោះពុកមិននៅយូរប៉ុន្មានទេ ពុកជិតចូលរណ្តៅហើយ!”

ពេលនោះ នាងសម័យដើរចេញពីផ្ទះមក មានកាន់អាវមកបំពាក់អោយប្តីផង ហើយនិយាយថា:

— “យី! បងឯងមានការអ្វីក៏និយាយច្រើនម្លេះ? និយាយអោយវាខ្លីៗទៅ កុំបរិហារវែងពេក ព្រោះដល់ម៉ោងទៅស៊ីការគេហើយណ៎ះ!”

— “ម៉ោងប៉ុន្មានហើយអូន?” មឿនងាកទៅសួរប្រពន្ធ។

នាងសម័យលើកដៃមើលនាឡិកា រួចប្រាប់ប្តីថា:

— “ម៉ោងជិត ៧ហើយ នៅខ្វះតែ ១០នាទីទៀតទេ ទៅ! តិចមិនទាន់ពេលគេ... ទៅ!”

នាងសម័យដឹកដៃប្តីតំរង់ទៅរថយន្ត។ មឿនក៏ដើរតាមប្រពន្ធទៅ តែងាកក្បាលមកបញ្ចេញសំលេងទៅកាន់ឪពុកខ្លួនថា:

— “នៅហ្នឹងសិនហើយ ខ្ញុំទៅស៊ីការគេមួយភ្លែត!”

បន្ទាប់មករថយន្តពើហ្ស (៤០៤) ថ្មីក៏រត់ចេញយ៉ាងលឿនទៅក្រៅរបងផ្ទះ ចំនែកតាកសិករយើងសម្លឹងពីក្រោយមឿន និងសម័យដោយកំលាំងទោសៈ ទ្រាំមិនបានសំលេងក្រេវក្រោធក៏ផ្ទុះឡើងថា: “ហ៊ឺះ! អាមឿន! អាមឿនកូនពុក អាឯងភ្លេចហើយឬថាពូជអាឯងជាអ្នកស្រែ? អាឯងភ្លេចហើយឬថា អាម៉ែននិងអាម៉ន វាផ្តល់បុណ្យសក្តិដល់ក្បាលអាឯង? ឥឡូវអាឯងបែរខ្នងអោយអញ មិនអីទេអានាង! ទេវតាមានភ្នែក អាក្រពើវង្វេងបឹង! បុណ្យលោក បុណ្យតេជគុណរបស់អាឯងនេះ មុខជាមិនឋិតថេរប៉ុន្មានទេ អានាង!”

ដកស្រង់ពីរឿង “កូនអកតញ្ញូ”
និពន្ធដោយ អ៊ុំ សំអាង